| IV- Manufacturing-Related Services | | |
|---|---|---|
| | NIL | NIL |
| **V- Other Services** | | |
| | NIL | NIL |

TEL-SL-NT

★★★

## អនុក្រឹត្យលេខ ៨១ អនក្រ.បក
## ស្តីពីការបង្កើតសហគ្រាសសាធារណៈ
## ភ្នាក់ងារកម្ពុជានាវាចរ ហៅថា កាំសាប

***

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/៣០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញ អនុក្រឹត្យលេខ ៩១ អនក្រ .បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តន៍ព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានការឯកភាពពីគណៈរដ្ឋមន្ត្រី នាសម័យប្រជុំពេញអង្គ ថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៩

## សំរេច

### ជំពូកទី១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-** ត្រូវបានបង្កើតសហគ្រាសសាធារណៈ ដែលមានលក្ខណៈជាក្រុមហ៊ុនរដ្ឋ ឈ្មោះ ភ្នាក់ងារកម្ពុជានាវាចរ ហៅថា កាំសាប ដែលស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រោមអាណាព្យាបាលហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

- កាំសាប មានទីស្នាក់ការកណ្តាលនៅរាជធានីភ្នំពេញ អាគារលេខ២ និង១០៩ ក ផ្លូវវិថី សេរ៉េ ធូន ក៏ង ស៊ីសុវត្ថិ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ និងសាខាក៏សាបនៅក្រុងព្រះសីហនុ
- កាំសាប គឺជានីតិបុគ្គលប្រកបដោយស្វ័យភាព ផ្នែកបច្ចេកទេស ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ
- កាំសាប ត្រូវក្រោមឥទ្ធិពលបទប្បញ្ញត្តិនៃអនុក្រឹត្យនេះហើយនិងគោរពតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ។

**មាត្រា ២.-** កាំសាប មានភារកិច្ចធ្វើអាជីវកម្ម សេវាលើការងារ :

១- ធ្វើជាតំណាងឲ្យម្ចាស់នាវា ឬអ្នកជួលនាវា រួមទាំងពាក់ព័ន្ធនឹងសេវា អាជីវកម្មនាវាសមុទ្រ ទន្លេនៅតំបន់ដែនព្រះរាជាណាចក្រកម្ពុជា និងជួយលើកទឹកចិត្តទំនាក់ទំនងសេដ្ឋកិច្ចដឹកជញ្ជូនតាមនាវាសមុទ្រ ទន្លេជាមួយប្រទេសក្រៅ ។

២- ចាត់ចែងសំឡាប់ឲ្យនាវាចូល និងចេញពីតំបន់ដែន នៃព្រះរាជាណាចក្រកម្ពុជា ។

៣- ស្នើសុំអ្នកនាំផ្លូវ និងតំណាងឲ្យនាវា ។

៤- ទាក់ទងសំរួលការលើកដាក់ ផ្ទេរ ផ្ទុក ទទួល ប្រគល់ វាស់ ថ្លឹង រាប់ ទំនិញក្នុងឃ្លាំង លើទីលាន ឬលើផែ និងសំរួលទំនិញឲ្យបានល្អដូចដើម ឆាវ៉ាញ់ប៉ែ ឡើងដែលខូចខាត ធ្លុះធ្លាយបាត់បង់ ឬខ្វះបុកប្រឡាក់ ព្រមទាំងចូលរួមដោះស្រាយបណ្តឹងតវ៉ាចំពោះទំនិញទាំងនេះ ។

៥- ជាភ្នាក់ងារកណ្តាលក្នុងការជួល ទិញ លក់ ប្រគល់ ទទួល កាន់កាប់ ប្រើប្រាស់នាវា និងទាក់ទងនឹងការជួល ដឹក ផ្ទុក រើ បញ្ជូន និងត្រៀមកន្លែងផ្ទុកទំនិញ ព្រមទាំងចុះហត្ថលេខាតាងនាមម្ចាស់នាវា ឬអ្នកជួលនាវាលើកិច្ចសន្យាទាំងនោះ ។

៦- សម្រួលការផ្តល់ជូន ការពិនិត្យលក្ខណៈបច្ចេកទេសនាវា ធ្វើពាក្យសុំត្រួតពិនិត្យ ឬបញ្ជាក់ថា សម្ភារសង្គ្រោះជីវិតបំពាក់ក្នុងកៅអីអាចប្រើបាន ។

៧- ត្រៀមកន្លែង រៀបចំទម្រង់ការឥវ៉ាន់ និងអ្នកដំណើរ ឡើង ចុះនាវា ។

៨- សម្រួលការចេញនាវិកឡើងគោក ដើម្បីទំនាក់ទំនងកិច្ចការផ្សេងៗ ជាមួយ ភ្នាក់ងារមានសមត្ថកិច្ច ឬក្រសួងនានាធ្វើទស្សនកិច្ច ព្យាបាលជំងឺនៅមន្ទីរពេទ្យ ធ្វើមាតុភូមិនិវត្តន៍ ផ្លាស់នាវិកពីនាវាមួយទៅនាវាមួយផ្សេងទៀត ឬធ្វើដំណើរតាមផ្លូវទឹក ផ្លូវគោក និងផ្លូវអាកាស ។

៩- សម្រួលការផ្គត់ផ្គង់ម្ហូបអាហារ ទឹកសាប ប្រេងឥន្ធនៈ កន្ទេល ក្តារបន្ទះ ឬស៊ី ក្តារក្រដាស ប្រដាប់ជួសជុលគ្រឿងចក្រ សំភារៈ និងឧបករណ៍ផ្សេងៗ ដល់នាវាក្នុងករណីត្រូវការ ។

១០- ប្រមូល និងផ្ទេរប្រាក់ឈ្នួលនាវា ប្រាក់សំណងសង្គ្រោះបន្ទាន់ ដោះស្រាយប្រាក់រង្វាន់ ឬប្រាក់ពិន័យក្នុងការលើកដាក់ទំនិញ ។

១១- ចាត់ចែងជួយសង្គ្រោះនាវាក្នុងពេលមានគ្រោះថ្នាក់ ហើយចូលរួមដោះស្រាយប្រាក់ សំណង និងប្រាក់រង្វាន់នៃការជួយសង្គ្រោះនាវា ។

១២- សម្រួលទំនាក់ទំនងការងារ រវាងម្ចាស់នាវា និងកំពង់ផែ ម្ចាស់ទំនិញ ស្ថាប័នរដ្ឋ ក្នុងពេលនាវាស្ថិតនៅកំពង់ផែ ដើម្បីដោះស្រាយបញ្ហា និង សំណូមពរនានារបស់ម្ចាស់នាវា ហើយផ្តល់ព័ត៌មានអំពីសកម្មភាពនាវានៅកំពង់ផែ ។

១៣- ចាត់ចែងគ្រប់គ្រង ក្នុងករណីដឹកជញ្ជូនបន្ត ធ្វើការដឹកជញ្ជូនតាមផ្លូវទឹក គោក និង អាកាស បំពេញភារកិច្ចជាភ្នាក់ងារប្រតិបត្តិការ ភ្នាក់ងារបញ្ជូនទំនិញ ភ្នាក់ងារការពារនាវា ។

១៤- ធ្វើការងារ អាហារដ្ឋាន និវាសដ្ឋាន និងគ្រប់គ្រងសណ្ឋាគារ សំរាប់ជួយ ឲ្យម្ចាស់នាវា អ្នកជួលនាវា និងនាវិក ។

១៥- បន្តនិរន្តរភាពការកិច្ចម្ចាស់នាវា ឬអ្នកជួលនាវាឲ្យមានប្រសិទ្ធភាពជាមួយកាំសាប រួមមានដូចខាងក្រោមនេះ :

- ការចុះកិច្ចសន្យាអាចធ្វើតាមរយៈទូរលេខ ឬ លិខិត
- លក្ខណៈសម្បត្តិនៃនាវា
- ព័ត៌មាននៃការមកដល់របស់នាវា

- ប្រាក់កក់នៅធនាគារ
- ឯកសារដឹកជញ្ជូននាវាចរសមុទ្រ ទន្លេ ។

មាត្រា ៣.- កាំសាប មានសិទ្ធិ :

- ទទួលខុសត្រូវ និងចាត់ចែងក្នុងការងារការពារសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់លើការងាររបស់ខ្លួន
- ប្រកាន់គោលការណ៍ និងរបៀបកិច្ចការដូចគ្នានឹងអាជីវករ
- គ្រប់គ្រងដឹកនាំ និងចាត់ចែងសកម្មភាពឲ្យមានប្រសិទ្ធភាព និងមានការរីកចំរើន
- ក្នុងឋានៈជាស្ថាប័នសាធារណៈ កាំសាប ទទួលពីរដ្ឋនូវសិទ្ធិ និងភារកិច្ចទាំងឡាយ ដើម្បីបំពេញបេសកកម្មស្របតាមកម្មវត្ថុរបស់ខ្លួន ។

មាត្រា ៤.- លើកលែងតែបទប្បញ្ញត្តិផ្ទុយនេះ កាំសាប ត្រូវបង់ពន្ធអាករ ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

មាត្រា ៥.- ដើមទុនដំបូងនៃ កាំសាប ត្រូវកំណត់ដោយបញ្ជីតុល្យការចាប់ផ្តើម ដែលបានទទួលការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយក្រសួងសាធារណការ និងដឹកជញ្ជូន ។

ពេលដែលអនុក្រឹត្យនេះ ចូលជាធរមាន កាំសាបត្រូវចាត់ទុកជាម្ចាស់កម្មសិទ្ធិពេញច្បាប់ជំនួសរដ្ឋលើទ្រព្យសម្បត្តិទាំងអស់ ដែលបានកត់ត្រាក្នុងបញ្ជីសារពើភ័ណ្ឌ ។

មាត្រា ៦.- បុគ្គលិករបស់ កាំសាប ត្រូវគ្រប់គ្រងដោយលក្ខន្តិកៈ ដោយឡែកដែលអនុម័តដោយក្រុមប្រឹក្សាភិបាល ។

## ជំពូកទី២

## ការដឹកនាំ និង គ្រប់គ្រង

មាត្រា ៧.- កាំសាប ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសិទ្ធិពេញលេញ ដើម្បីបំពេញការងារក្នុងក្របខ័ណ្ឌ បទប្បញ្ញត្តិនៃអនុក្រឹត្យនេះ និងបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

ក្រុមប្រឹក្សាភិបាលមានសមាសភាព ដូចខាងក្រោម :

- តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន ០១រូប ជាប្រធាន
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ០១រូប ជាសមាជិក
- តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ០១រូប ជាសមាជិក
- តំណាងក្រសួងមហាផ្ទៃ ០១រូប ជាសមាជិក
- តំណាងក្រសួងពាណិជ្ជកម្ម ០១រូប ជាសមាជិក

- តំណាងនិយោជិតរបស់ **កាំសាប** ០១រូប ជាសមាជិក
- អគ្គនាយក **កាំសាប** ០១រូប ជាសមាជិក

**មាត្រា ៨.-** សមាជិកក្រុមប្រឹក្សាភិបាល ជ្រើសរើសក្នុងចំណោមមន្ត្រីដែលសកម្ម ធ្លាប់បានបំពេញការងារយ៉ាងតិច ០៥ (ប្រាំ) ឆ្នាំ ឬជាឥស្សរជនដែលមានអាយុ មិនលើសពី ៦៥ឆ្នាំ និងមានបទពិសោធន៍ការងារគ្រប់គ្រាន់ព្រមទាំងមានជំនាញ ខ្ពស់ក្នុងវិស័យសេដ្ឋកិច្ច វិទ្យាសាស្ត្រ ឬនីតិសាស្ត្រ ដែលមានសញ្ជាតិខ្មែរ និងពុំដែលមានទីណ្ឌកម្មពីបទឧក្រិដ្ឋពីគុណកម្មធ្ងន់ធ្ងរ ។

- សមាជិកក្រុមប្រឹក្សាភិបាល ត្រូវតែងតាំងដោយអនុក្រឹត្យសំរាប់អាណត្តិ ០៣ឆ្នាំ ។ អាណត្តិនេះអាចបញ្ចប់បានគ្រប់ពេលវេលា និងអាចបន្តទៀតបាន ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួង ឬអាជ្ញាធរ ដែលខ្លួនតំណាងឲ្យ ។
- តំណាងនិយោជិត ត្រូវជ្រើសរើសដោយបោះឆ្នោតក្នុងចំណោមនិយោជិត **កាំសាប** ។

**មាត្រា ៩.-** ក្រុមប្រឹក្សាមានសិទ្ធិពេញលេញ ដើម្បីសំរេចក្នុងនាម **កាំសាប** ក្នុងការរៀបចំពិនិត្យតាមដានលើរាល់ប្រតិបត្តិការផ្សេងៗ ទាក់ទងនឹងកម្មវត្ថុរបស់សហគ្រាស ស្របតាមច្បាប់ជាធរមាន ។

**ក្រុមប្រឹក្សាភិបាលមានតួនាទីដូចតទៅ**

១- ផ្តល់ការយល់ព្រមលើគោលការណ៍សហគ្រាស ដូចចែងក្នុងមាត្រា១៨ នៃអនុក្រឹត្យនេះ ។
២- វាយតំលៃរៀងរាល់ពេលនូវលទ្ធផលដែលបានគ្រោងទុក ព្រមទាំងចាត់វិធានការណ៍ ដើម្បីកែសំរួលឲ្យបានសមស្របតាមសភាពការណ៍ ។
៣- ផ្តល់ការយល់ព្រមលើគុណវិបាក គណនីប្រចាំឆ្នាំ និងរបាយការណ៍សកម្មភាពរបស់ **កាំសាប** ។
៤- សំរេចតាមសំណើរបស់អគ្គនាយកនូវចំនាត់ថ្នាក់ និងបេឡាផ្ទៃក្នុងរបស់សហគ្រាស ព្រមទាំងលក្ខន្តិកៈ និងការប្រាក់បៀវត្ស ប្រាក់រង្វាន់ ប្រាក់ឧបត្ថម្ភផ្សេងៗសំរាប់បុគ្គលិក ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិទាំងឡាយជាធរមាន ។
៥- ផ្តល់ការយល់ព្រមលើកិច្ចសន្យា និងអនុសញ្ញាដែល **កាំសាប** ជាភាគីបត្តូលេខី ស្របតាមលក្ខខ័ណ្ឌ និងបែបបទដូចមានចែងក្នុងបទប្បញ្ញត្តិជាធរមាន ។
៦- សំរេចបង្កើត បើក ឬបិទការិយាល័យ និងទីភ្នាក់ងារគ្រប់ទីកន្លែងរបស់ **កាំសាប** តាមការវិនិច្ឆ័យរបស់ខ្លួន ។
៧- កំណត់ថ្លៃឈ្នួលដែលពាក់ព័ន្ធ និងអាជីវកម្ម សេវាកាំសាប ។

មាត្រា ១០.- ក្រុមប្រឹក្សាភិបាល បើកអង្គប្រជុំគ្រប់ពេល អាស្រ័យដោយអត្ថប្រយោជន៍ នៃសាលាគ្រាស តាមការអញ្ជើញរបស់ប្រធាន ឬតាមសំណើនៃសមាជិកដែលមានបួននាក់យ៉ាងតិច ក្នុងចំណោមសមាជិកទាំងអស់ ។

ទោះយ៉ាងណាក៏ដោយ ក្រុមប្រឹក្សាត្រូវធ្វើការប្រជុំយ៉ាងតិច ១ដង ក្នុងរយៈពេល ០៣ខែ ។

ក្នុងករណីប្រធានមានធុរៈ ត្រូវជ្រើសរើសសមាជិកម្នាក់ ដែលមានវ័យចំណាស់ជាងគេដើម្បីដឹកនាំការប្រជុំ ។

ក្រុមប្រឹក្សា ត្រូវពិភាក្សាលើបញ្ហាទាំងឡាយ ដែលស្ថិតក្នុងក្របខ័ណ្ឌរបស់ខ្លួន ។

របៀបវារៈ នៃការប្រជុំព្រមទាំងឯកសារភ្ជាប់ទាំងឡាយ ត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូប និងមន្ត្រីត្រួតពិនិត្យរដ្ឋឲ្យបានយ៉ាងតិច ១០ថ្ងៃ មុនពេលបើកអង្គប្រជុំ ។

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល អាចប្រព្រឹត្តទៅបានលុះណាតែមានវត្តមានសមា-ជិកយ៉ាងតិចពាក់កណ្ដាល ។ បើសិនជាមិនគ្រប់កូរ៉ុមទេ ការប្រជុំត្រូវលើកទៅ ១៥ថ្ងៃក្រោយទៀត ដើម្បីពិភាក្សាឡើងវិញលើបញ្ហាតាមរបៀបវារៈដដែល ។ កិច្ចប្រជុំលើកក្រោយនេះ ពុំចាំបាច់ទាមទារកូរ៉ុមទេ ។

សេចក្ដីសំរេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាល អាចយកជាការបានលុះត្រាតែមានការអនុម័តដោយសំឡេងភាគច្រើននៃសមាជិកអង្គប្រជុំ ។បើសិនជាការបែកសំឡេងមានចំនួនស្មើគ្នា សំលេងរបស់ក្រុមប្រឹក្សាភិបាល ឬប្រធានអង្គប្រជុំត្រូវចាត់ទុកជាឧត្តមានុភាព ។

មាត្រា ១១ .- សេចក្ដីសំរេចនៃក្រុមប្រឹក្សាភិបាលត្រូវកត់ត្រាក្នុងកំណត់ហេតុមួយ ដែលត្រូវបញ្ជូនទៅអាជ្ញាធរអាណាព្យាបាល ទៅសមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗ និងមន្ត្រីត្រួតពិនិត្យរដ្ឋ ព្រមទាំងស្ថាប័នដទៃទៀត ដែលមានចែងក្នុងមាត្រា២៥ នៃអនុក្រឹត្យនេះ ក្នុងរវាង១៥ថ្ងៃ យ៉ាងយូរចាប់រាប់ពីថ្ងៃប្រជុំ ។

កំណត់ហេតុដើម ត្រូវមានចុះហត្ថលេខាដោយប្រធាននៃអង្គប្រជុំ និងសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ ដែលមានវត្តមានក្នុងកិច្ចប្រជុំពេលនោះ ។

មាត្រា ១២.- អគ្គនាយកមានភារកិច្ចជាអ្នកគ្រប់គ្រងការងារជាប្រចាំ និងត្រូវបានតែងតាំងសំរាប់អាណត្តិ ០៣ឆ្នាំ ដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួងអាណាព្យាបាលបច្ចេកទេស ។

មាត្រា ១៣.- ក្រុមប្រឹក្សាភិបាល ប្រគល់ជូនអគ្គនាយកឲ្យទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សាភិបាល នូវអំណាចចាំបាច់សំរាប់ដំណើរការប្រចាំថ្ងៃ ដើម្បីមានលទ្ធភាពគ្រប់គ្រាន់សំរាប់ដឹកនាំសហគ្រាសស្របតាមច្បាប់ និងការណែនាំរបស់ក្រុមប្រឹក្សាភិបាល ។

**ក្នុងក្របខ័ណ្ឌនេះ អគ្គនាយកត្រូវ :**

១- រៀបចំឯកសារទាំងឡាយ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលចាត់ចែងអនុវត្តរាល់សេចក្ដីសំរេចរបស់ក្រុមប្រឹក្សាភិបាល តាមដំណាក់កាលនីមួយៗ អគ្គនាយកត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាលអំពីសកម្មភាពរបស់ **កាំសាប** ។

២- ទទួលដឹកនាំ **កាំសាប** លើផ្នែករដ្ឋបាល បច្ចេកទេស អាជីវកម្ម សេវា និងហិរញ្ញវត្ថុ ។

៣- តំណាង **កាំសាប** ចំពោះមុខតតិយជនទាំងឡាយក្នុងការបំពេញលិខិតស្នាមស៊ីវិល រដ្ឋបាល ឬលិខិតតុលាការក្នុងក្របខ័ណ្ឌច្បាប់ និងការសំរេចរបស់ក្រុមប្រឹក្សាភិបាល។

៤- មានសិទ្ធិជ្រើសរើស តែងតាំង ដកហូតតំណែង ឬបញ្ឈប់ការងារ និងមានសិទ្ធិបញ្ជាត្រួតត្រាបណ្ដាភ្នាក់ងារ ឬមន្ត្រីគ្រប់រូប ដែលជានិយោជិតរបស់ **កាំសាប** ដោយគោរពតាមលក្ខន្តិកៈបុគ្គលិក ឬ ច្បាប់ជាធរមាន និង តាមការសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

៥- មានសិទ្ធិផ្ទេរអំណាចមួយភាគ ឬទាំងអស់រួមទាំងផ្ទេរសិទ្ធិចុះហត្ថលេខាទៅមន្ត្រីដែលនៅក្រោមឱវាទស្របតាមលក្ខខ័ណ្ឌដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាល ។

តំណាងឲ្យ **កាំសាប** ចំពោះមុខតុលាការ និងសាលាជំរះក្ដីគ្រប់ជាន់ថ្នាក់ ក្នុងការចោទប្រកាន់ តវ៉ាការពារក្ដីឲ្យ **កាំសាប** និងការប្ដឹងជំទាស់ផ្សេងៗ ។

មាត្រា ១៤.- លាភការរបស់ក្រុមប្រឹក្សាភិបាល និងប្រាក់បំណាច់របស់អគ្គនាយក ត្រូវកំណត់ដោយក្រសួងអាណាព្យាបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

មាត្រា ១៥.- ការចុះ និងការអនុវត្តន៍កិច្ចសន្យាដោយ **កាំសាប** ត្រូវគោរពតាមបែបបទ និងនីតិវិធីដែលកំណត់ ដោយច្បាប់ជាធរមាន ។

## ជំពូកទី ៣

## ការគ្រប់គ្រងហិរញ្ញវត្ថុ

មាត្រា ១៦.- **កាំសាប** កាន់កាប់គណនេយ្យរបស់ខ្លួន ឲ្យបានត្រឹមត្រូវតាមបទបញ្ញាគណនេយ្យកម្ពុជា និងតាមវិធាននៃគណនេយ្យ ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ការិយបរិច្ឆេទគណនេយ្យចាប់ផ្តើមពីថ្ងៃ ០១ ខែមករា ហើយបញ្ចប់នៅថ្ងៃ ៣១

ខែធ្នូ នៃឆ្នាំដដែល ។

តុល្យការ និងគណនីគ្រប់គ្រងត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល មុនថ្ងៃ ៣០ ខែ

មិនា នៃឆ្នាំបន្ទាប់ (ឆ្នាំបិទការិយបរិច្ឆេទ) ឈរលើបាយការណ៍នៃគណនេយ្យករជំនាញ

ដែលមានមុខងារជាស្នងការគណនី ។

តុល្យការ និងគណនីគ្រប់គ្រង ព្រមទាំងរបាយការណ៍របស់ស្នងការគណនី ត្រូ

ដាក់សុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងកំឡុងពេលមិនលើសពី ១៥ថ

រាប់ពីថ្ងៃដែលក្រុមប្រឹក្សាភិបាលបានពិនិត្យឯកសារទាំងឡាយ ។ ឯកសារទាំងនេះ ត្រូ

បញ្ជូនទៅក្រសួងអាណាព្យាបាលផងដែរ ដើម្បីសុំមតិទៅតាមលក្ខខណ្ឌដែលមានចែ

ក្នុងមាត្រា ១៦ នៃច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ។

មាត្រា ១៧.- ស្នងការគណនី ត្រូវបានតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និ

ហិរញ្ញវត្ថុសំរាប់អាណត្តិ បីការិយបរិច្ឆេទ ។

លាភការរបស់ស្នងការគណនី ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល ដែលមានក

យល់ព្រមពីរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងត្រូវចំណាយក្នុងបន្ទុកអាជីវក

របស់ គាំសាប ។

ស្នងការគណនី ត្រូវធ្វើរបាយការណ៍ដើម្បីបញ្ជាក់គណនីប្រចាំឆ្នាំនៃការិយបរិ

មានភាពស្មោះត្រង់ និងត្រឹមត្រូវល្អ ហើយឆ្លុះបញ្ចាំងអំពីភាពពិតប្រាកដ នៃស្ថានភ

ហិរញ្ញវត្ថុរបស់ គាំសាប ។

បេសកកម្មរបស់ស្នងការគណនី អនុលោមតាមបទប្បញ្ញត្តិនៃអនុក្រឹត្យលេខ

អនក្រ.បក ចុះថ្ងៃទី ០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីស្នងការគណនីសហគ្រាសសាធារណ

ស្នងការគណនីអាចចូលរួមប្រជុំជាមួយក្រុមប្រឹក្សាភិបាល បានតាមការអញ្ជើ

របស់ប្រធានក្រុមប្រឹក្សាភិបាល ។

មាត្រា ១៨.- យ៉ាងយូរណាស់ឆ្នាំមុនថ្ងៃ ០១ ខែតុលា ក្រុមប្រឹក្សាភិបាលត្រូវផ្តល់ការយល់ព្រមលើគំរោង

ការសហគ្រាសប្រចាំឆ្នាំ តាមសំណើរបស់អគ្គនាយក ហើយបញ្ជូនគំរោងនេះដើម្បី

ការអនុម័តពីរដ្ឋមន្ត្រីក្រសួងអាណាព្យាបាល និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គំរោងផែនការប្រចាំឆ្នាំ ត្រូវបញ្ជាក់ដូច :

១- កម្មវិធីវិនិយោគ ព្រមទាំងហិរញ្ញប្បទានបំរុងសំរាប់សកម្មវិធីវិនិយោគនេះ ។

២- ផែនការសំរាប់ដំណើរការនៃសហគ្រាស ។

៣- តំណែងបម្រើសេវានាវាចរណ៍ ។

៤- សេចក្តីណែនាំនិងគោលការណ៍ទូទៅរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់ កាំសាប ។

មាត្រា ១៩.- ធនធាននៃ កាំសាប មានជាអាទិ៍ :

- ប្រាក់ដើមទុនដែលរដ្ឋផ្តល់ឲ្យ (គុណតម្លៃការប៉ាន់ស្មាននៅពេលបង្កើត)
- ប្រាក់ចំណេញផ្សេងៗ គ្រប់ប្រភេទបានមកពីសកម្មភាពរបស់សហគ្រាស
- ប្រាក់បានមកពីការលក់ ឬការជួលចលនវត្ថុ និងអចលនវត្ថុរបស់ កាំសាប
- ប្រាក់ខ្ចីបុល និងប្រាក់សំណោកផ្សេងៗ

មាត្រា ២០.- ចំណាយនៃ កាំសាប រួមមាន :

- ចំណាយប្រព្រឹត្តសំរាប់ដំណើរការ
- ចំណាយវិនិយោគ
- សងបំណុល
- ចំណាយផ្សេងៗ

មាត្រា ២១.- កាំសាប អាចមានគណនីក្នុងធនាគារពាណិជ្ជកម្មផ្សេងៗ ហើយប្រើប្រាស់គណនីនេះ សំរាប់តំរូវការរបស់ខ្លួន ។

មាត្រា ២២.- ជារៀងរាល់ឆ្នាំក្រោយពីមានការសំរេចពី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រាក់ចំណេញដែល កាំសាប ទទួលបានពីការទូទាត់តាមវិធានគណនេយ្យ កាំសាប មានសិទ្ធិប្រើប្រាស់ប្រាក់ចំណេញនេះឲ្យសមស្របទៅតាមលក្ខខណ្ឌច្បាប់ ។

មាត្រា ២៣.- រដ្ឋធានាចំពោះតែបំណុលណា ដែលមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី៤

## ទំនាក់ទំនងជាមួយរដ្ឋ

មាត្រា ២៤.- រយៈពេល ១៥ថ្ងៃយ៉ាងយូរបំផុត ក្រោយពីការអនុម័តរបស់ក្រុមប្រឹក្សាភិបាល កាំសាប ត្រូវផ្ញើជូន រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអាណាព្យាបាល និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវឯកសារដូចមានខាងក្រោមនេះ :

- កំណត់ហេតុប្រជុំនៃក្រុមប្រឹក្សាភិបាល
- គំរោងផែនការរបស់សហគ្រាស ដូចមានចែងក្នុងមាត្រា ១៨ នៃអនុក្រឹត្យនេះ

- របាយការណ៍ស្តីពីសកម្មភាព តុល្យការ និងគណនីគ្រប់គ្រងទាំងឡាយរបស់ គាំសាច
- របាយការណ៍របស់សួងការគណនី

**មាត្រា ២៥.-** ត្រូវបានដាក់ឲ្យនៅអមគាំសាចនូវមន្ត្រីត្រួតពិនិត្យរដ្ឋម្នាក់ ដែលត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ មន្ត្រីត្រួតពិនិត្យរដ្ឋមាន សិទ្ធិចូលរួមគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល ហើយអាចផ្តល់យោបល់លើគ្រប់ចំណុច នៃរបៀបវារៈតែពុំមានសំឡេងអនុម័តឡើយ ។ មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវបំពេញបេសកកម្ម ដោយ អនុលោមតាមបទប្បញ្ញត្តិនៃមាត្រា ២០ ទៅ ២៥ នៃច្បាប់ ស្តីពីលក្ខន្តិកៈទូទៅនៃ សហគ្រាសសាធារណៈ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៦៩៦/ប ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**មាត្រា ២៦.-** បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ២៧.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី និងរដ្ឋលេខាធិការនៃក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអគ្គនាយកភ្នាក់ងារកម្ពុជាអាកាស ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី

| | |
|---|---|
| រដ្ឋមន្ត្រីក្រសួងសាធារណការ | រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច |
| និង ដឹកជញ្ជូន | និងហិរញ្ញវត្ថុ |
| **ឃី តាំងលីម** | **គាត ឈន់** |

***